# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation
លេខ: ៦៤៦ MISTI / ២០២២

# ប្រកាស
## ស្តីពី
## ការអនុវត្តគោលការណ៍ទូទៅនៃអនាម័យម្ហូបអាហារ នៅក្នុងរោងចក្រ សហគ្រាស និងសិប្បកម្ម

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃ២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្តង់ដារកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១១ ចុះថ្ងៃ២៦ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីស្តង់ដារកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ប្រកាសលេខ ០០២ MISTI/២០២២ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ ស្តីពីការផ្តល់វិញ្ញាបនបត្របញ្ជាក់អនាម័យ
- បានឃើញកិច្ចសម្រុះសម្រួលទទួលស្គាល់គ្នាទៅវិញទៅមកតាមផ្នែកអាស៊ាន សម្រាប់ប្រព័ន្ធអធិការកិច្ច និងវិញ្ញាបនបត្រកម្ម ស្តីពីអនាម័យម្ហូអាហារសម្រាប់ផលិតផលម្ហូបអាហារដែលបានរៀបចំរួច ដែលបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាននាថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៨
- យោងតាមតម្រូវការចាំបាច់របស់ក្រសួង



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីមែល: misti.smcabinet@gmail.com

# សម្រេច

**ប្រការ១ .-**

ប្រកាសនេះ មានគោលបំណង៖

- ដាក់ឱ្យអនុវត្តកម្មវិធីអនាម័យប្រកបដោយប្រសិទ្ធភាពនៅក្នុងខ្សែចង្វាក់ផលិតកម្ម
- ធ្វើឱ្យប្រសើរឡើងនូវគុណភាពផលិតផលម្ហូបអាហារ ធានាបាននូវសុវត្ថិភាពដល់អ្នកបរិភោគ និងការពារសុខុមាលភាពសាធារណៈ
- ផ្តល់លទ្ធភាពដល់ផលិតផលក្នុងស្រុកក្នុងការប្រកួតប្រជែងជាមួយផលិតផលនាំចូល និងអាចនាំចេញ
- ផ្តល់វិញ្ញាបនបត្របញ្ជាក់អនាម័យសម្រាប់ផលិតកម្មម្ហូបអាហារ។

**ប្រការ២ .-**

ប្រកាសនេះ មានគោលដៅដាក់ឱ្យអនុវត្តស្តង់ដារកម្ពុជា CS 468:2014 ស្តីពីគោលការណ៍ទូទៅនៃអនាម័យម្ហូបអាហារនៅក្នុងខ្សែសង្វាក់ផលិតកម្មម្ហូបអាហារ និងស្តង់ដារកម្ពុជា CS 084:2010 ស្តីពីគោលការណ៍ និងការតម្រូវរួមរបស់អាស៊ានសម្រាប់អនាម័យម្ហូបអាហារ។

**ប្រការ៣ .-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះរោងចក្រ សហគ្រាស និងសិប្បកម្មម្ហូបអាហារនៅក្នុងព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះ។

**ប្រការ៤ .-**

វាក្យសព្ទដែលប្រើនៅក្នុងប្រកាសនេះ មានអត្ថន័យ និងការបកស្រាយ ដូចខាងក្រោម៖

**រោងចក្រ សហគ្រាស និងសិប្បកម្ម** សំដៅលើអាគារ ទីកន្លែង ឬ យានយន្ត សម្រាប់ផលិត បំប្លែងវត្ថុធាតុដើម ឬផលិតផលពាក់កណ្តាលសម្រេចឱ្យទៅជាផលិតផលថ្មី ឬ/និង សម្រាប់ធ្វើសកម្មភាពផ្សេងទៀត ដែលមានជាអាទិ៍ ផ្គុំ ដំឡើង ជួសជុល ធ្វើតេស្ត វេចខ្ចប់ ប្រកបំពេញ ថែទាំ រក្សាទុក កែលម្អ ដើម្បីបម្រើសេចក្តីត្រូវការទីផ្សារ។

**ម្ហូបអាហារ** សំដៅដល់ សារធាតុណាមួយ ទោះបីជាបានកែច្នៃ ពាក់កណ្តាលកែច្នៃ ឬ មិនទាន់កែច្នៃ ដែលបម្រើដល់ការបរិភោគរបស់មនុស្ស និងរួមបញ្ចូលទាំងភេសជ្ជៈ ស្ករកៅស៊ូ និងសារធាតុណាមួយដែលត្រូវបានប្រើប្រាស់ក្នុងកម្មន្តសាល ការរៀបចំ ឬ ការប្រព្រឹត្តកម្មនៃម្ហូបអាហារ។

**វិញ្ញាបនបត្រកម្ម** សំដៅដល់ នីតិវិធីដែលអង្គភាពវិញ្ញាបនបត្រកម្មផ្លូវការ និងអង្គភាពវិញ្ញាបនបត្រកម្មដែលទទួលស្គាល់ជាផ្លូវការ ផ្តល់នូវការធានាជាលាយលក្ខណ៍អក្សរ ឬដែលមានតម្លៃស្មើ ថាម្ហូបអាហារ ឬប្រព័ន្ធត្រួតពិនិត្យម្ហូបអាហារ អនុលោមទៅនឹងការតម្រូវ អាចផ្អែកលើកម្រិតនៃសកម្មភាពអធិការកិច្ច ដែលអាចរួមបញ្ចូលទាំងអធិការកិច្ចអនឡាញ សវនកម្មលើប្រព័ន្ធគ្រប់គ្រងគុណភាព និងការត្រួតពិនិត្យផលិតផលសម្រេចជាបន្តបន្ទាប់។

**វិញ្ញាបនបត្រផលិតផល** សំដៅដល់វិញ្ញាបនបត្រលាយលក្ខណ៍អក្សរដែលចេញដោយវិទ្យាស្ថានស្តង់ដារកម្ពុជា ដើម្បីបញ្ជាក់ថាផលិតផលមួយ បានអនុលោមទៅតាមការតម្រូវរបស់ស្តង់ដារផលិតផល ដែលបានកំណត់ និងទទួលបានអាជ្ញាប័ណ្ណសម្រាប់ប្រើសញ្ញាបញ្ជាក់ផលិតផល។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខៈ (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.stcabinet@gmail.com

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

**វិញ្ញាបនបត្របញ្ជាក់អនាម័យ** សំដៅដល់ វិញ្ញាបនបត្រលាយលក្ខណ៍អក្សរដែលចេញដោយវិទ្យាស្ថានស្តង់ដារកម្ពុជា ដើម្បីបញ្ជាក់ថាប្រព័ន្ធត្រួតពិនិត្យម្ហូបអាហារ បានអនុលោមទៅតាមស្តង់ដារអនាម័យដែលបានកំណត់។

**វិញ្ញាបនបត្របញ្ជាក់ភាពអនុលោម** សំដៅដល់ ឯកសារជាលាយលក្ខណ៍មួយដែលចេញដោយអង្គភាពវាយតម្លៃភាពអនុលោម ដើម្បីផ្តល់នូវការជឿទុកចិត្តថាផលិតផលមួយ ឬ ដំណើរការមួយ ឬ សេវាកម្មណាមួយបានបញ្ជាក់យ៉ាងត្រឹមត្រូវថាបានអនុលោមទៅតាមការតម្រូវពាក់ព័ន្ធ។

**អង្គភាពមានសមត្ថកិច្ច** សំដៅដល់ នាយកដ្ឋានវិញ្ញាបនបត្រកម្ម នៃវិទ្យាស្ថានស្តង់ដារកម្ពុជានៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលមានសមត្ថកិច្ចតាមប្រកាសលេខ ១៣៩ MISTI/២០២០ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានវិញ្ញាបនបត្រកម្ម។

**ការវាយតម្លៃភាពអនុលោម** សំដៅដល់ ការត្រួតពិនិត្យជាលក្ខណៈប្រព័ន្ធ ដើម្បីកំណត់វិសាលភាពដែលផលិតផល ដំណើរការ ឬ សេវាកម្ម បំពេញតាមការតម្រូវកំណត់។

**នីតិវិធីនៃការវាយតម្លៃភាពអនុលោម** សំដៅដល់ នីតិវិធីណាមួយដែលប្រើប្រាស់ដោយផ្ទាល់ ឬ ដោយប្រយោល ដើម្បីកំណត់ថា ការតម្រូវពាក់ព័ន្ធនៅក្នុងបទប្បញ្ញត្តិបច្ចេកទេស ឬ ស្តង់ដារ ត្រូវបានបំពេញ។

**ផលិតកម្ម** សំដៅដល់ ការផលិត ការកែច្នៃ ការវេចខ្ចប់ និងការស្តុកទុកផលិតផល។

**ទីផ្សារ** សំដៅដល់ ទីកន្លែងធ្វើអាជីកម្មលក់ ផ្គត់ផ្គង់ ចែកចាយ លក់ដុំ និងលក់រាយផលិតផលនៅលើទីផ្សារ។

## ប្រការ៥ ..

ម្ចាស់រោងចក្រ សហគ្រាស និងសិប្បកម្ម ដែលផលិត កែច្នៃ វេចខ្ចប់ និងស្តុកទុកផលិតផលម្ហូបអាហារសម្រាប់ចរាចរនៅលើទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា ឬសម្រាប់នាំចេញទៅបរទេស ត្រូវអនុលោមតាមស្តង់ដារកម្ពុជា CS 468:2014 ស្តីពីគោលការណ៍ទូទៅនៃអនាម័យម្ហូបអាហារ និងស្តង់ដារកម្ពុជា CS 084:2010 ស្តីពីគោលការណ៍ និងការតម្រូវរួមរបស់អាស៊ានសម្រាប់អនាម័យម្ហូបអាហារ ជាដាច់ខាត និងត្រូវមានវិញ្ញាបនបត្របញ្ជាក់អនាម័យ ដែលចេញដោយនាយកដ្ឋានវិញ្ញាបនបត្រកម្ម នៃវិទ្យាស្ថានស្តង់ដារកម្ពុជា នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

## ប្រការ៦ ..

នាយកដ្ឋានវិញ្ញាបនបត្រកម្ម ត្រូវចេញវិញ្ញាបនបត្របញ្ជាក់អនាម័យ យ៉ាងយូរត្រឹម ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីរោងចក្រ និងសិប្បកម្ម បានដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់អនាម័យ ដោយមានភ្ជាប់ជូនមកជាមួយនូវឯកសារចាំបាច់ គ្រប់គ្រាន់ និងត្រឹមត្រូវ។

បែបបទ និងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្របញ្ជាក់អនាម័យ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

វិញ្ញាបនបត្របញ្ជាក់អនាម័យ មានសុពលភាពរយៈពេល ៣ (បី) ឆ្នាំ។

## ប្រការ៧ ..

កម្រៃសេវាសម្រាប់ការចេញវិញ្ញាបនបត្របញ្ជាក់អនាម័យ ត្រូវកំណត់តាមប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

**ប្រការ៨ ._**

ឯកសារទាំងឡាយ ដែលនឹងត្រូវរាប់បញ្ចូលទៅក្នុងសំណុំឯកសារចាំបាច់ រួមមាន៖

(១) ប្រកាស/សេចក្តីសម្រេចអនុញ្ញាតបើករោងចក្រ/សិប្បកម្ម ចេញដោយក្រសួង/មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មានសុពលភាព ........................................១ច្បាប់

(២) គំនូសប្លង់ទីតាំងផលិតកម្ម និងគំនូសប្លង់អាគារផលិតកម្ម និងទីតាំងឧបករណ៍..........១ច្បាប់

(៣) គំនូសបំព្រួញខ្សែសង្វាក់ផលិតកម្ម........................................................................១ច្បាប់

(៤) បញ្ជីឧបករណ៍ម៉ាស៊ីនប្រើក្នុងការផលិត..................................................................១ច្បាប់

(៥) បញ្ជីរាយឈ្មោះវត្ថុធាតុដើម...................................................................................១ច្បាប់

(៦) រូបថតពណ៌ក្នុងខ្សែសង្វាក់ផលិតកម្មទាំងមូល (វីដេអូ ក្នុងករណីចាំបាច់).............១០សន្លឹក

(៧) ច្បាប់ចម្លងវិញ្ញាបនបត្របញ្ជាក់អនាម័យ (ករណីសុំបន្តសុពលភាព)....................១ច្បាប់។

**ប្រការ៩ ._**

ក្នុងករណីម្ចាស់រោងចក្រ សហគ្រាស និងសិប្បកម្ម ដែលផលិត កែច្នៃ វេចខ្ចប់ និងស្តុកទុកផលិតផលម្ហូបអាហារ សម្រាប់ចរាចរនៅលើទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា ឬ សម្រាប់នាំចេញទៅបរទេស មិនបានអនុលោមតាមស្តង់ដារកម្ពុជា CS 468:2014 ស្តីពីគោលការណ៍ទូទៅនៃអនាម័យម្ហូបអាហារ និងស្តង់ដារកម្ពុជា CS 084:2010 ស្តីពីគោលការណ៍និងការតម្រូវរួមរបស់អាស៊ានសម្រាប់អនាម័យម្ហូបអាហារ និងមិនបានទទួលវិញ្ញាបនបត្របញ្ជាក់អនាម័យពីនាយកដ្ឋានវិញ្ញាបនបត្រកម្ម នៃវិទ្យាស្ថានស្តង់ដារកម្ពុជា នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ស្តីពីស្តង់ដារកម្ពុជា និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីស្តង់ដារកម្ពុជា។

**ប្រការ១០ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១១ ._**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានមជ្ឈមណ្ឌល ប្រធាននាយកដ្ឋានវិញ្ញាបនបត្រកម្ម និងគ្រប់អង្គភាពក្រោមឱវាទក្រសួង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ១៣រោច ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០២២

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

***កិត្តិសេដ្ឋាបណ្ឌិត* ចម ប្រសិទ្ធ**

**កន្លែងទទួល៖**

- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងព័ត៌មាន
- ក្រសួងយុត្តិធម៌
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ៖ (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel